**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :១០៨ /០០៨ /២០០៦

ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០៦

**សេចក្តីសម្រេច**

លេខ :០៨០/០០៧ / ២០០៦ កបធ.ច

ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៧៧/០០៤/២០០៦ កបធ.ច ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០០៦
- បានឃើញសេចក្តីសម្រេចលេខ ០៧៦ /០៦០៦/ ពស/ សរ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើបទបញ្ជាផ្ទៃក្នុងថ្មីរបស់ព្រឹទ្ធសភា
- បានឃើញលិខិតលេខ ០៨០ / ០៦០៦ /ពស/នវ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០៦ របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ដែលព្រឹទ្ធសភាបានអនុម័តដោយមានសម្លេងយល់ព្រមចំនួន ៥៩ លើ ៥៩ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០០៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី១ នីតិកាលទី២ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០០៦ វេលាម៉ោង ១៦:៣០នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សំណើរបស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ស្របនឹងមាត្រា១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ប្រការ ២ថ្មី មិនមានអ្វីដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ប្រការ ៤ ថ្មី ( ប្រការ ៥ ចាស់ កែប្រែ) ស្របនឹងមាត្រា ១០៦ថ្មី( មួយ) នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ប្រការ១៨ថ្មី (ប្រការ ១៩ ចាស់ កែប្រែ) ស្របនឹងមាត្រា១០៦ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ប្រការ ៤២ ថ្មី (ប្រការ ៤៣ ចាស់ កែប្រែ) និង ប្រការ១០៥ ថ្មី ( ប្រការ ១០៦ ចាស់ កែប្រែ) មិនមានអ្វីដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ប្រការ ១០៨ ថ្មី (ប្រការ ១០៩ ចាស់ កែប្រែ) ស្របនឹងមាត្រា ១១៤ ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ ។

## សម្រេច

**មាត្រា ១.** តាមមូលបទខាងលើ វិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលព្រឹទ្ធសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី ១ នីតិកាលទី២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី០៥ ខែ កក្កដា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

មិន សិន